ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៤២ មស.ចល

# របាយការណ៍
# ស្តីពីវឌ្ឍនភាពការងារប្រចាំខែមករា ឆ្នាំ២០១៦
# និងកម្មវិធីការងារបន្តរបស់ក្រសួងមុខងារសាធារណៈ

នៅក្នុងរយៈពេលមួយខែកន្លងទៅនេះ ក្រសួងមុខងារសាធារណៈបានអនុវត្តការងារនិងសម្រេចភារកិច្ចសំខាន់ៗដូចខាងក្រោម៖

## I.សកម្មភាពថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំក្រសួងបានអញ្ជើញចូលរួមកិច្ចប្រជុំ ការងារសង្គម និងពិធីផ្សេងៗរួមមាន៖ (១)អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី (២)ចូលរួមនិងដឹកនាំអង្គប្រជុំអន្តរក្រសួង (៣)អង្គប្រជុំពាក់ព័ន្ធនឹងការប្រឡងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី៩ នៅសាលាភូមិន្ទរដ្ឋបាល (៤)អង្គប្រជុំផ្ទៃក្នុង ដើម្បីកែលម្អគេហទំព័រ និងបណ្តាញសង្គមឱ្យកាន់តែមានភាពទាក់ទាញ (៥)ចូលរួមវេទិកាសាធារណៈទៅតាមមុខសញ្ញាកំណត់ និង(៦)ចូលរួមកម្មវិធីនានាតាមការអញ្ជើញរបស់គណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ ក្រសួង ស្ថាប័ននានា។

## II.សកម្មភាពជំនាញ

### ១.អង្គភាពថ្នាក់ជាតិ

#### ១.១.ការងារគ្រប់គ្រងបុគ្គលិក

ក.ការគ្រប់គ្រងស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ

- គិតត្រឹមខែមករា ឆ្នាំ២០១៦ ក្រសួងមានមន្ត្រីរាជការសរុបចំនួន៦២៨នាក់/ស្ត្រី១៦៩នាក់ (ថ្នាក់កណ្តាលសរុបចំនួន៤២០នាក់/ស្ត្រី១១៨នាក់ និង ថ្នាក់ក្រោមជាតិចំនួន២០៨នាក់/ស្ត្រី៥១នាក់)
- ស្ថិតិមន្ត្រីរាជការចាប់ពីរដ្ឋមន្ត្រីមកដល់មន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ៖ (១)រដ្ឋមន្ត្រីនិងឋានៈស្មើរដ្ឋមន្ត្រីចំនួន០៣នាក់ (២)រដ្ឋលេខាធិការនិងឋានៈស្មើរដ្ឋលេខាធិការចំនួន០៥នាក់/ស្ត្រី០១នាក់ (៣)អនុរដ្ឋលេខាធិការនិងឋានៈស្មើអនុរដ្ឋលេខាធិការចំនួន១៣នាក់/ស្ត្រី០៣នាក់ (៤)អគ្គនាយកនិងឋានៈស្មើអគ្គនាយកចំនួន០៥នាក់ (៥)អគ្គនាយករងចំនួន១៣នាក់/ស្ត្រី០៤នាក់ (៦)អគ្គាធិការចំនួន០១នាក់ (៧)អគ្គាធិការរងចំនួន០២នាក់ (៨)អធិការចំនួន០៧នាក់/ស្ត្រី០២នាក់ (៨)ប្រធាននាយកដ្ឋាននិងឋានៈស្មើប្រធាននាយកដ្ឋានចំនួន១៩នាក់/ស្ត្រី០៣នាក់ (៩)ប្រធានអង្គភាពលទ្ធកម្មចំនួន០១នាក់ (១០)អនុប្រធាននាយកដ្ឋាន និងឋានៈស្មើអនុប្រធាននាយកដ្ឋានចំនួន៨៣នាក់/ស្ត្រី១៩នាក់ (១១)ប្រធានការិយាល័យចំនួន៥៥នាក់/ស្ត្រី១៨នាក់ (១២)អនុប្រធានការិយាល័យចំនួន៥១នាក់/ស្ត្រី២០នាក់ (១៣)មន្ត្រីចំនួន១៦២នាក់/ស្ត្រី៤៨នាក់។

ខ.ការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រី

| ល.រ | បរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | ការតែងតាំងនិងប្រគល់ភារកិច្ចជូនមន្ទីរ មស រាជធានី ខេត្តព្រៃវែង និងខេត្តស្វាយរៀង | ០៦ | |
| ២ | សំណើសុំចូលបម្រើការងារក្នុងក្របខណ្ឌវិញរបស់មន្ត្រី | ០៤ | |
| | សរុប | ១០ | |

គ.ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល

- វគ្គបណ្តុះបណ្តាលក្នុងប្រទេស៖ បានបញ្ជូនមន្ត្រីចំនួន១១នាក់(ស្ត្រី០៣នាក់) ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "Basic English Language and Communication Skills II" និង "JDS Feedback Session with faculty members of the Japanese Universities" ។
- វគ្គបណ្តុះបណ្តាលក្រៅប្រទេស៖ បានបញ្ជូនមន្ត្រីចំនួន០៦នាក់ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី (១)"សន្តិភាពសកល ក្នុងសតវត្សន៍ទី២១ ការទទួលខុសត្រូវរបស់អាស៊ី" នៅព្រះរាជាណាចក្រថៃ (២) "Productivity and Innovation Focusing on Performance Management" នៅប្រទេសចិន (៣) "Certificate of Proficiency in English and IT Skills" នៅប្រទេសឥណ្ឌា និង (៤)"Public Personnel Administration for Middle Level Officials" នៅប្រទេសជប៉ុន។

១.២.ការងារនីតិកម្មនិងវិវាទមុខងារសាធារណៈ

- បានចូលរួមប្រជុំអន្តរក្រសួងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន និង អនុក្រឹត្យស្តីពី (១)ការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភីជនពិការក្នុងការប្រកួតប្រជែងមុខជំនាញ ការប្រកួតកីឡាស្បៀស្យាល់អូឡាំពិក និងប្រាក់ឧបត្ថម្ភគ្រូបង្វឹកជំនួស (២)ការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា (៣)វិធានការហាមការដាក់និងការបង្ហយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការនិងកន្លែងសាធារណៈ និង (៤)ការដំឡើងឋានៈវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈឱ្យមានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាន
- បានឆ្លើយតបចំពោះសំណើសុំ (១)កែឈ្មោះការិយាល័យចំណុះនាយកដ្ឋាននានានៃក្រសួងកិច្ចការនារី និង (២)បង្កើតការិយាល័យផលិតកម្មស្អាតស្ថិតក្នុងរចនាសម្ព័ន្ធគ្រប់គ្រង របស់មជ្ឈមណ្ឌលផលិតភាពជាតិ នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានចាត់មន្ត្រីរាជការចំនួន០១រូប ដើម្បីចូលរួមក្នុងក្រុមការងារបច្ចេកទេស នៃគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់សម្រាប់រៀបចំសេចក្តីព្រាងគោលនយោបាយសម្រាប់មនុស្សចាស់។

១.៣.ការងារគ្រប់គ្រងក្របខណ្ឌ

- បានប្រជុំពិភាក្សា (១)ដើម្បីពិនិត្យលើការគ្រប់គ្រងនិងការប្រើប្រាស់គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា និង មន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងធម្មការនិងសាសនាឆ្នាំ២០១៥-២០១៦ (២)លើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត និង សារាចរណែនាំស្តីពីនីតិវិធីនៃការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរអង្គភាព រាជធានី ខេត្ត
- បានលក់និងទទួលពាក្យប្រឡងចូលក្របខណ្ឌក្រសួងធម្មការនិងសាសនា
- បានធ្វើការបែងចែកផែនការប្រើប្រាស់ក្របខណ្ឌ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ឆ្នាំ២០១៦ និងបានរៀបចំគម្រោងសម្រាប់ឆ្នាំ២០១៧
- បានរៀបចំសំណើសុំលើកការរៀបចំប្រឡងជ្រើសរើសបេក្ខជន ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៥ ហើយបញ្ចូលក្នុងផែនការក្របខណ្ឌឆ្នាំ២០១៦
- បានចាត់មន្ត្រីចំនួន០២រូប ដើម្បីចូលរួមក្នុងគណៈកម្មការប្រឡងជ្រើសរើសសិស្ស និស្សិតចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងផែនការ

- បានផ្តល់ទិដ្ឋាការលើសំណើសុំ៖

| ល.រ. | ក្រសួង-ស្ថាប័ន | ក្របខណ្ឌថ្មី | | | | ក្របខណ្ឌពិសេស | កិច្ចសន្យា | អណ្តែត | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | ក | ខ | គ | | | | |
| ក.ថ្នាក់កណ្តាល | | | | | | | | | |
| ១ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | | | ០៨ | | | |
| ២ | អភិវឌ្ឍន៍ជនបទ | | | | | ០១ | | | |
| ៣ | វប្បធម៌និងវិចិត្រសិល្បៈ | | | | | ០៦ | | | |
| ៤ | ធម្មការនិងសាសនា | | | | | ០១ | | | |
| ៥ | រដ្ឋ.អាកាសចរណ៍ស៊ីវិល | | | | | ០៣ | | | |
| ៦ | អង្គភាពប្រឆាំងអំពើពុករលួយ | ៥៥ | ៤៩ | ០២ | ០៤ | | | | |
| | សរុប | ៥៥ | ៤៩ | ០២ | ០៤ | ១៩ | | | |
| ខ.ថ្នាក់រាជធានី-ខេត្ត | | | | | | | | | |
| ១ | មន្ទីរផែនការខេត្តកំពង់ចាម | ១២ | ១២ | | | | | | |
| ២ | មន្ទីរផែនការខេត្តត្បូងឃ្មុំ | ១២ | ១០ | ០២ | | | | | |
| ៣ | មន្ទីរផែនការខេត្តក្រចេះ | ១២ | ១០ | ០២ | | | | | |
| ៤ | មន្ទីរផែនការខេត្តស្វាយរៀង | ១២ | ០៧ | ០៥ | | | | | |
| ៥ | មន្ទីរផែនការខេត្តកំពង់ឆ្នាំង | ១០ | ០៧ | ០៣ | | | | | |
| ៦ | មន្ទីរផែនការខេត្តរតនគិរី | ១០ | ០៨ | ០២ | | | | | |
| ៧ | មន្ទីរផែនការខេត្តមណ្ឌលគិរី | ១០ | ០៥ | ០៥ | | | | | |
| ៨ | មន្ទីរផែនការខេត្តកែប | ១០ | ០៨ | ០២ | | | | | |
| ៩ | មន្ទីរផែនការខេត្តកំពត | ១៣ | ១០ | ០៣ | | | | | |
| ១០ | មន្ទីរផែនការខេត្តកណ្តាល | ១២ | ១០ | ០២ | | | | | |
| | សរុប | ១១៣ | ៨៧ | ២៦ | | | | | |

១.៤.ការងារត្រួតពិនិត្យរដ្ឋបាលនិងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

- បានធ្វើសំណើសុំសេចក្តីសម្រេចពីសម្តេចនាយករដ្ឋមន្ត្រីនិងផ្តល់ទិដ្ឋាការជូនក្រសួងស្ថាប័នដូចខាងក្រោម៖

| ល.រ | ការបរិយាយ | សំណើសុំការសម្រេចពីសម្តេចនាយករដ្ឋមន្ត្រី | | ផ្តល់ទិដ្ឋាការជូនក្រសួងស្ថាប័ន | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១ | ផ្ទេរក្របខណ្ឌ | ០១ | | ៣៤ | ០៣ |
| ២ | តែងតាំង | ១១ | ០២ | ២៧ | ០៨ |
| ៣ | តាំងស៊ប់ | ២៩ | ០៦ | | |
| ៤ | បូលនិវត្តន៍ | ៦២ | ០៦ | ១៥ | |
| ៥ | រៀបរៀវត្ស | | | ០២ | |
| ៦ | កែសម្រួលប្រាក់បំណាច់មុខងារ | | | ០២ | |
| | សរុប | ១០៣ | ១៤ | ៨០ | ១១ |

- បានពិនិត្យ និង ផ្តល់យោបល់លើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ចំនួន៣៦សំណុំលិខិត និង សលាកប័ត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិលចំនួន៧២នាក់ (ស្ត្រី២០នាក់)។

១.៥.ការងារគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានិងឯកសារមន្ត្រីរាជការស៊ីវិល

- បាន(១)ឆ្លើយតបនិងដោះស្រាយសំណួរតាមប្រព័ន្ធ Hot Line បានចំនួន២៥ករណី (២)បញ្ចូលទិន្នន័យដែលទទួលបានពីការចុះត្រួតពិនិត្យលើការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការ ជាគ្រូបង្រៀន និងផ្នែករដ្ឋបាល គ្រូ

បង្រៀនជាប់កិច្ចសន្យាចំនួនប្រាំខេត្ត (៣)រៀបចំកែសម្រួលប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការស៊ីវិល និងតារាងទូទាត់បៀវត្សឱ្យស្របតាមសារាចរ ស្តីពីការកែសម្រួលនីតិវិធី នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ (៤)ថែទាំកុំព្យូទ័រ Servers និង Clients (៥)ថែទាំប្រព័ន្ធគ្រប់គ្រងព័ត៌មាននិងទូទាត់បៀវត្សមន្ត្រីរាជការស៊ីវិល បណ្ដាញអ៊ីនធឺណិត សារអេឡិចត្រូនិច គេហទំព័រ និងបណ្ដាញសង្គមហ្វេសប៊ុក និង (៦)កំពុងរៀបចំប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច

- បានរកឃើញប្រាក់បៀវត្សមិនប្រក្រតីចំនួន ៣០៥,៥៦០,២៩០៛ ដែលត្រូវបង្វែរចូលក្នុងថវិកាជាតិវិញ
- បានថតចម្លងសលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិលជាផ្លូវការចំនួន០១នាក់ និង បានធ្វើសេចក្តីជូនដំណឹងដល់ក្រសួង ស្ថាប័ននានាចំនួន០៤នាក់
- បានបញ្ចូលទិន្នន័យមន្ត្រីរាជការស៊ីវិលក្នុងប្រព័ន្ធបណ្ណសារចំនួន៦២៤នាក់ រៀបចំសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលឡើងធ្វើចំនួន១៣២៦នាក់ និង បញ្ចូលចលនាប្រែប្រួលស្តីពីទីតាំងសលាកប័ត្ររបស់មន្ត្រីរាជការស៊ីវិលចំនួន១៦០៣២២នាក់/១៧០១២៤នាក់ ដែលមានក្នុងកម្មវិធីគ្រប់គ្រងឯកសារឯកត្តជនមន្ត្រីរាជការស៊ីវិល
- បានធ្វើការកែតម្រូវការប្រែប្រួលស្ថានភាពរបស់មន្ត្រីរាជការ (ឯកតា=នាក់) ដូចខាងក្រោម ៖

| ល.រ | បរិយាយ | ថ្នាក់កណ្តាល | ថ្នាក់រាជធានី-ខេត្ត |
|---|---|---|---|
| ១ | មន្ត្រីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៣៣ | ៦១ |
| ២ | មន្ត្រីចូលបម្រើការងារវិញក្រោយពីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៦០ | ៩១ |
| ៣ | មន្ត្រីក្របខណ្ឌថ្មី | ១៥ | ១២៧ |
| ៤ | មន្ត្រីតាំងស៊ប់ | ៩៣ | ២៥៤ |
| ៥ | មន្ត្រីឡើងឋានៈ | ២២៩ | ១៣៩ |
| ៦ | មន្ត្រីដល់អាយុចូលនិវត្តន៍ | ២៩ | ២៦ |
| ៧ | មន្ត្រីលុបឈ្មោះចេញពីតារាងទូទាត់បៀវត្ស | ២៥ | |
| ៨ | មន្ត្រីប្តូរឋានន្តរសក្តិ | | ៤៦ |
| ៩ | មន្ត្រីនៅក្រៅក្របខណ្ឌដើម | | ០២ |
| ១០ | មន្ត្រីឡើងថ្នាក់ប្រចាំឆ្នាំ | ១១ | ០៥ |
| ១១ | មន្ត្រីឡើងឋានន្តរស័ក្តិ | ០៦ | |
| ១២ | មន្ត្រីទីប្រឹក្សា | ១៦ | |
| ១៣ | មន្ត្រីផ្ទេរចេញ | ៣៥ | ៥២១ |
| ១៤ | មន្ត្រីផ្ទេរចូល | ៤០ | ១៨៥ |
| ១៥ | មន្ត្រីសុំប្រាក់បំណាច់មុខងារ | ០១ | ៣៨ |
| ១៦ | បញ្ចូលកូន | ៧៩ | ៣៩៩ |
| ១៧ | បញ្ចូលប្រពន្ធ | ១២ | ៨៥ |
| ១៨ | មន្ត្រីលាឈប់ពីការងារ | | ២៥ |
| ១៩ | មន្ត្រីស្លាប់ | | ១១ |
| ២០ | មន្ត្រីសុំដកប្រាក់បំណាច់មុខងារ | ០១ | |
| ២១ | មន្ត្រីប្តូរក្របខ័ណ្ឌ | ៤០ | ៣២១ |
| | សរុប | ៧២៥ | ២៣៣៦ |

**១.៦.ការងារមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជានិងកិច្ចសហប្រតិបត្តិការអន្តរជាតិ**

- បានសម្របសម្រួល និង ឆ្លើយតបជាមួយលេខាធិការដ្ឋានអាស៊ាន ស្តីពីការកែសម្រួលគម្រោង ACCSM+3 របស់កម្ពុជា ស្តីពី "ASEAN Minimum on Public Service Standard"
- បានធ្វើសំណើសុំពន្យាលិខិតឆ្លងដែនការទូតជូនមន្ត្រីជាន់ខ្ពស់០១នាក់ ដែលត្រូវចូលរួមទស្សនកិច្ចសិក្សាស្តីពី "Productivity and Innovation Focusing on Performance Management" នៅប្រទេសចិន
- បានធ្វើសំណើសុំទិដ្ឋាការជូនមន្ត្រី០១នាក់ ដើម្បីចូលរួមបណ្តុះបណ្តាលស្តីពី "Public Personnel Administration for Middle Level Officials" នៅប្រទេសជប៉ុន

- បានប្រមូល និង តាក់តែងកិច្ចការស្រាវជ្រាវស្ដីពីវិស័យមុខងារសាធារណៈរបស់បណ្ដាប្រទេសអាស៊ាន និង អាស៊ាន+៣ ។

១.៧.ការងារអគ្គាធិការដ្ឋាន

- បានចុះទៅសាលាខណ្ឌព្រែកព្នៅ និង ខណ្ឌពោធិ៍សែនជ័យ ដើម្បីពិនិត្យនិងកែសម្រួលនីតិវិធីក្នុងការតែងតាំងប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិឱ្យស្របទៅតាមសេចក្ដីណែនាំលេខ២២០២មស.សណន
- បានចុះអធិការកិច្ចករណីមន្ត្រីឈ្មោះ ហ៊ីត ស្រីអេម ក្របខណ្ឌពីកន្លែង នៃមន្ទីរអប់រំ យុវជន និង កីឡាខេត្តព្រះវិហារ ដែលមានឈ្មោះដូចគ្នា ទីកន្លែងកំណើតដូចគ្នា អត្តលេខខុសគ្នា ភេទខុសគ្នា និងកំពុងមានឈ្មោះពីរក្នុងតារាងបៀវត្ស។

១.៨.សាលាភូមិន្ទរដ្ឋបាល

- បានរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៩ ដោយមានការចូលរួមសហការពី១៦ក្រសួង ស្ថាប័នដើម្បីធ្វើជាអ្នកសង្កេតការណ៍ អ្នកសួរសំណួរផ្ទាល់មាត់ និងជានាតម្លាភាពក្នុងការប្រឡង
- បានរៀបចំលិខិត (១)ទៅ៣៦ក្រសួងស្ថាប័នរដ្ឋ ដើម្បីចាត់មន្ត្រីរាជការស៊ីវិលចូលរួមប្រឡងប្រជែងជ្រើសរើសកម្មសិក្សាការីជាន់ខ្ពស់និងមធ្យមចូលរៀនវគ្គបណ្ដុះបណ្ដាលបន្តសម្រាប់ឆ្នាំ២០១៦ (២)ជូនក្រសួងមហាផ្ទៃក្រសួងការពារជាតិ និងក្រសួងកិច្ចការនារី ដើម្បីរៀបចំវគ្គបណ្ដុះបណ្ដាលនៅសាលាភូមិន្ទរដ្ឋបាល ស្ដីពី "ការបណ្ដុះបណ្ដាលយោធិន និងនគរបាលជាតិ" និង "ថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ"
- បានប្រជុំពិភាក្សាការងារជាមួយអ្នកជំនាញការកូរ៉េ ដើម្បីអភិវឌ្ឍន៍កម្មវិធីបណ្ដុះបណ្ដាល នៃវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និង មធ្យម
- បាននឹងកំពុងរៀបចំសេចក្ដីព្រាងអនុស្សរណៈយោគយល់គ្នា រវាងសាលាភូមិន្ទរដ្ឋបាល និង សាកលវិទ្យាល័យសាន់សានខុសនៃប្រទេសអូស្ត្រាលី។

១.៩.ការងារសវនកម្មផ្ទៃក្នុង

- បានជូនដំណឹងដល់មន្ទីរមុខងារសាធារណៈខេត្តមណ្ឌលគិរី និង ខេត្តស្វាយរៀង ស្ដីពីតម្រូវការឯកសារសម្រាប់ចុះប្រមូលព័ត៌មាន និង ធ្វើសវនកម្ម និង បានចុះធ្វើសវនកម្មនៅមន្ទីរមុខងារសាធារណៈខេត្តមណ្ឌលគិរី
- បានប្រជុំផ្ទៃក្នុងរបស់នាយកដ្ឋាន ដើម្បី (១)បង្កើតគណៈកម្មការរៀបចំកិច្ចការសវនកម្ម រដ្ឋបាល បុគ្គលិកផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ (២)ពិព័ណនាអំពីមុខតំណែងថ្នាក់ដឹកនាំនិងមន្ត្រីក្នុងនាយកដ្ឋាន និង(៣)ការពង្រឹងវិន័យនិងការងារក្នុងនាយកដ្ឋាន។

១.១០.ការងារអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ

- នាយកដ្ឋានទាំងប្រាំនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ បានរៀបចំផែនការសកម្មភាព និងផែនការថវិកាឆ្នាំ២០១៦របស់នាយកដ្ឋាននីមួយៗរួចរាល់ហើយ
- ដោយឡែកនាយកដ្ឋានសេវាសាធារណៈបានកំណត់សកម្មភាពសំខាន់ៗរួមមាន៖ (១)ការរៀបចំលិខិតបទដ្ឋានគតិយុត្ត (២)ជម្រុញការអនុវត្តការកែលម្អគុណភាពសេវាសាធារណៈ (៣)ការដាក់ឱ្យដំណើរការនូវយន្តការផ្ដល់ព័ត៌មានត្រឡប់ និង បណ្ដឹងតវ៉ារបស់អ្នកប្រើប្រាស់ (៤)ជម្រុញការផ្ដល់សេវាតាមប្រព័ន្ធព័ត៌មានវិទ្យា (៥)បង្កើត និង ដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និង វាយតម្លៃគុណភាព និង ប្រសិទ្ធភាពនៃការផ្ដល់សេវា (៦)បញ្ចប់កម្រងព័ត៌មានសេវាសាធារណៈ (៧)បណ្ដុះបណ្ដាលមន្ត្រីបង្គោល និង រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ព្រមទាំងបោះពុម្ពឯកសារ ស្ដីពីសេវាសាធារណៈ នៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានប្រជុំឆ្លងថ្នាក់ដឹកនាំនូវសេចក្ដីព្រាង ស្ដីពីការផ្ដល់សេវាសាធារណៈ តាមយន្តការច្រកចេញចូលតែមួយរបស់ក្រសួងមុខងារសាធារណៈ
- បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ លើគម្រោងសិក្សាស្រាវជ្រាវ ស្ដីពីការបង្កើតកម្មវិធីលើទូរស័ព្ទដៃសាកល្បងសម្រាប់ផ្ដល់ព័ត៌មានអំពីសេវាសាធារណៈ

- បាននិងកំពុងសិក្សាលទ្ធភាពចុះសិក្សាដោយផ្ទាល់នៅមន្ទីរពេទ្យបង្អែកខេត្តព្រៃវែង កំពត ក្រចេះ និងកំពង់ធំ ដើម្បីត្រៀមបង្កើតនិងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីដំណើរការនៃការគ្រប់គ្រងនិងការវិភាគទិន្នន័យនៅនាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃនិងធ្វើបទបង្ហាញ ស្តីពីមុខងារចេនាសម្ព័ន្ធ និងនីតិវិធីបំពេញការងាររបស់អង្គភាពធនធានមនុស្ស សម្រាប់កិច្ចការផ្ទៃក្នុងរបស់លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានធ្វើទស្សនកិច្ចសិក្សា ស្តីពី "ផលិតភាពនិងនវានុវត្តភាពដោយផ្តោតលើការគ្រប់គ្រងប្រសិទ្ធភាពការងារ" នៅប្រទេសចិន
- បានចូលរួមប្រជុំជាមួយប្រតិភូ Civil Service College និង មូលនិធិ TEMASEK របស់ប្រទេសសិង្ហបុរី ដើម្បីពិនិត្យលើវឌ្ឍនភាពនៃគម្រោងសិក្សាលើមុខងារ ចេនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្ស
- បានប្រជុំកម្រិតលេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ លើសេចក្តីព្រាងឯកសារណែនាំ ស្តីពី "ប្រព័ន្ធគ្រប់គ្រងគុណផល"
- បានរៀបចំតារាងស្ទង់មតិ ស្តីពីតម្រូវការបណ្តុះបណ្តាលរយៈពេលខ្លីៗ សម្រាប់នាយកដ្ឋាននានាចំណុះឱ្យអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ។

១.១១.<u>ការកែទម្រង់ប្រព័ន្ធបៀវត្ស (ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស)</u>

- បានរៀបចំនិងដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ ១៩១ អនក្រ.បក ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដោយបានបង្កើនបៀវត្សអប្បបរមារបស់ (១)មន្ត្រីរាជការស៊ីវិលដល់ ៧០០៥០០រៀល (២)វិស័យអប់រំនិងសុខាភិបាលដល់ ៨០០៥០០រៀល (៣)នគរបាលជាតិដល់ ៧៨៤៧៣០រៀល និង(៤)យោធិនដល់ ៧៣៣៧៣០រៀល
- បានរៀបចំអង្គប្រជុំអន្តរក្រសួង ដើម្បីពិនិត្យនិងពិភាក្សាលើខ្លឹមសារសេចក្តីព្រាងអនុក្រឹត្យ ស្តីពី (១)ការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត (២)ការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា
- បានប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ (១)សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការប្រឡងផ្លាស់ប្តូរទីកន្លែងធ្វើការរបស់មន្ត្រីរាជការនិងការប្រឡងជ្រើសរើសក្របខណ្ឌថ្មី (២)ការអនុវត្តការកាត់ពន្ធលើបៀវត្សមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិសម្រាប់ឆ្នាំ២០១៦ (៣)ការកែសម្រួលប្រាក់បំណាច់មុខងារជូនយោធិន មន្ត្រីនគរបាលជាតិ និងអនុរក្សពន្ធនាគារនៃក្រសួងមហាផ្ទៃ (៤)ការប្រមូលទិន្នន័យបឋមមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងសុខាភិបាល និង(៥)ការរៀបចំរបបសន្តិសុខសង្គមជូនបុគ្គលិកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីន កម្ពុជា។

១.១២.<u>ក្រុមការងារយេនឌ័រ</u>

- បានចូលរួមប្រជុំពិនិត្យ និងផ្តល់យោបល់លើខ្លឹមសារសេចក្តីព្រាងរបាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងារឆ្នាំ២០១៥ និង ផែនការសកម្មភាពការងារឆ្នាំ២០១៦ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- បានចូលរួមប្រជុំត្រៀមរៀបចំសន្និសីទស្តីពីស្ត្រីលើកទី៣ សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖ ធ្វើឱ្យគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដំណើរការសម្រាប់ស្ត្រីនិងក្មេងស្រីនៅប្រទេសកម្ពុជា ។

២.អង្គភាពថ្នាក់ក្រោមជាតិ

២.១.ការប្រើប្រាស់ក្របខណ្ឌនិងឥណទានបៀវត្ស

| ល.រ | រាជធានី-ខេត្ត | ចំនួនមន្ត្រី/បុគ្គលិក មន្ទីរ.ម.ស | | | | ចំនួនមន្ត្រីទូទាំង រាជធានី-ខេត្ត | | ប្រពន្ធ | កូន | ឥណទានបៀវត្ស | ចំនួនមន្ត្រីជាប់កិច្ចសន្យា | ចំនួនបុគ្គលិកអណ្ដែត | ផ្សេងៗ[1] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | កិច្ចសន្យា | អណ្ដែត | សរុប | ស្រី | | | | | | |
| ១ | ប.មានជ័យ | ៨ | ១ | | | ៧៩៤២ | ៣៣១៤ | ២៥៨៤ | ៦០២៧ | ៦១១៧៥០៦៧៨០ | | | ១៩៧ |
| ២ | បាត់ដំបង | ១៥ | ៣ | | | ១២០៤១ | ៥៧២៨ | ៣៣៣៤ | ១០៤៤២ | ៩៧៧០១១៤៨៨០ | | | |
| ៣ | កំពង់ចាម | ១០ | ៣ | | | ៩៨៩៤ | ៤៦៩៧ | ៣០៩៣ | ១០៧៤៥ | ៧៨១៤២៩២៩៤០ | | | ០១ |
| ៤ | កំពង់ឆ្នាំង | ១០ | ២ | ៣ | ២ | ៥៩៤៩ | ២៤៤១ | ២០១៨ | ៥៨០៤ | ៤៣១៤៣៨៤៨៨០ | ៤៦៤ | ១៦៥ | ១១ |
| ៥ | កំពង់ស្ពឺ | ៧ | ៣ | | | ៧២៨៤ | ២៧០៧ | ២៩៨២ | ៧៤៨៤ | ៥៩២១៤៨០៧៨០ | | | ១៨៥ |
| ៦ | កំពង់ធំ | ៩ | ២ | ៣ | ២ | ៧០២៤ | ៣១០៥ | ២២១២ | ៦៩៩១ | ៥៥៥១៦១៣៣៤០ | | | |
| ៧ | កំពត | ៩ | ២ | ៣ | ២ | ៧៩៩២ | ៣២៦៤ | ២៦៩៧ | ៧៤៤៩ | ៦៣៤៤៧២៧៥២០ | | | ៧១ |
| ៨ | កណ្ដាល | ៨ | ២ | ៣ | ២ | ១១៥៦៦ | ៥៣១៥ | ៣៨០៥ | ១១៨០៧ | ៨៤៧៦៩៣៥៨៤០ | ១៤៣ | ១៩៩ | ១០៤៦៩ |
| ៩ | កោះកុង | ៧ | ៣ | | | ២២០៨ | ៧៣៥ | ៦៥២ | ១៤៥៤ | ១៨១៦៧៨៦០៤០ | | | ៧៩ |
| ១០ | ក្រចេះ | ៧ | ១ | | | ៤៤៤១ | ២១៨១ | ១០០៧ | ៣៦៥៩ | ៣៤៦៥២០១៨៤៥ | | | ៩០ |
| ១១ | មណ្ឌលគិរី | ៧ | ៤ | ៣ | ២ | ១៦២៧ | ៦២៤ | ៣៨៤ | ៨០៨ | ១២៧៣៣២៧៨០០ | | | |
| ១២ | រាជធានីភ្នំពេញ | ១៣ | ៥ | ៣ | ២ | ១៤៣៨៧ | ៧៣៨៩ | ៣៨៩៣ | ១២២៩២ | ១២០៦៤៧៥៩៧៨០ | | | ៣៩៦៨ |
| ១៣ | ព្រះវិហារ | ១១ | ៤ | ៥ | | ៣៥១៦ | ១៣២៤ | ០៧ | ២៤ | ២៦៧២៩០៣៥០០ | | | ៨៣ |
| ១៤ | ព្រៃវែង | ១២ | ៤ | | | ១០០៤៥ | ៣៦៩៣ | ៤០៧៨ | ១១៧៨៤ | ៨១១៩៧២៦៧៣០ | | | |
| ១៥ | ពោធិ៍សាត់ | ១២ | ៦ | ៣ | ២ | ៥៤៣២ | ២១៦១ | ១៨២៥ | ៤៧២៤ | ៤២៨៩៣២១០០០ | | | ៣៧៥ |
| ១៦ | រតនគិរី | ១២ | | ៣ | ២ | ២៤២០ | ៨២០ | ៧១០ | ១៥០៦ | ១៩៤២១៨១៧៦៨ | ៤២១ | ១២០ | ៧១០ |
| ១៧ | សៀមរាប | ១៤ | ៣ | ៣ | ២ | ៩១៩០ | ៤៥៩១ | ២១១៨ | ៦៤៩៩ | ៧២៤២៧៨៩២៦០ | ២២៧០ | ៣៨៤ | ១៥១ |
| ១៨ | ព្រះសីហនុ | ៨ | ២ | | | ៣១៧៩ | ១២០៣ | ១០២៣ | ២៧៥៦ | ២៧០២៦៩៨៣១៩ | | | ៥៦ |
| ១៩ | ស្ទឹងត្រែង | ៥ | ៣ | ៥ | | ២៤៧៥ | ១០៥៦ | ៥៧២ | ១៤៥៧ | ១៩២៩៦៨១៣០០ | | | |
| ២០ | ស្វាយរៀង | ៩ | ២ | ៥ | | ៦៤៥៤ | ២០២៧ | ២៨១៨ | ៦៣១៨ | ៥១៥៩៧៧៣៦០៦ | | | ១៧៤ |
| ២១ | ត្បូងឃ្មុំ | ៣ | ១ | | | ៥៤៨៧ | ២៣៥១ | ១៦៧០ | ៥១២៣ | ៤៥០៣៤១៥៦៦០ | | | |
| ២២ | តាកែវ | ១១ | ១ | | | ១០៧០៨ | ៣៩៥២ | ៤៧១៤ | ១៥៦៧៧ | ៨០០៣៧០៥៨០០ | | | |
| ២៣ | កែប | ៦ | | | | ១១៩៣ | ៤៤៥ | ២៩០ | ៧៧៧ | ១០០០២២៦៩០០ | | | |
| ២៤ | ប៉ៃលិន | ៩ | ២ | | | ១៤៨៧ | ៥៣៨ | ៤៥២ | ៩៥៩ | ១៤០៤១១១៦៤៨ | | | |
| ២៥ | ឧត្ដរមានជ័យ | ៥ | | ៣ | ២ | ២៧១៨ | ៨៦១ | ៨៧៧ | ១៩៦២ | ២០៩៣៦៥៤៨០០ | | | |
| | សរុប | ២២៧ | ៥៩ | ៤៥ | ២០ | ១៥៦៦៥៩ | ៦៦៥២២ | ៤៩៨១៥ | ១៤៤៥២៨ | ១២៣៩៩៥៣២២៧១៦ | ៣២៩៨ | ៨៦៨ | ១៦៦២០ |

២.២.បញ្ហាប្រឈមក្នុងការអនុវត្តដែនសមត្ថកិច្ចរបស់មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត

- បន្ទប់ធ្វើការតូចចង្អៀតនិងខ្វះមធ្យោបាយបំពេញការងារ ( សម្ភារៈការិយាល័យនិងរថយន្ត )
- មិនទាន់មានមន្ត្រី ដើម្បីបំពេញរចនាសម្ព័ន្ធមន្ទីរ តាមប្រកាសលេខ ១៩៧៩ មស.គន ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- សមត្ថភាពមន្ត្រីនៅមានកម្រិត និងខ្វះឯកសារពាក់ព័ន្ធនឹងគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ជាពិសេសមិនបានយល់ច្បាស់ពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- អង្គភាពមួយចំនួនយឺតយ៉ាវក្នុងការបញ្ជូនសំណុំឯកសារប្រាក់បៀវត្ស ដើម្បីស្នើសុំទិដ្ឋាការពីមន្ទីរមុខងារសាធារណៈ

[1]ការប្រែប្រួលស្ថានភាពឋានៈនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល

- ខ្ទះថវិកាសម្រាប់ប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និង ច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការជូនមន្ទីរ-អង្គភាពជុំវិញខេត្ត។

III. **សេចក្តីសន្និដ្ឋាន**

អង្គភាពជំនាញទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ បានបំពេញការងារតាមទិសដៅដែលបានដាក់ក្នុងខែកន្លងមកសម្រេចបានលទ្ធផលជាវិជ្ជមាននិងគ្មានបញ្ហាអ្វីគួរឱ្យកត់សំគាល់ទេ។

IV. **ទិសដៅការងារ**

- រៀបចំដាក់សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច
- បន្តរៀបចំសេចក្តីព្រាង (១)ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋ (២) អនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជកាស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា
- បន្តសិក្សាស្រាវជ្រាវឯកសារលិខិតបទដ្ឋានផ្សេងៗ និងរៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បន្តទទួលពាក្យបណ្តឹង និង អង្កេតស្រាវជ្រាវពាក់ព័ន្ធនឹងវិវាទមុខងារសាធារណៈនិងបន្តចុះធ្វើអធិការកិច្ចអំពីភាពមិនប្រក្រតីក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិ
- បន្តអនុវត្តផែនការសកម្មភាព៣ឆ្នាំដំណាក់កាលទី២ (២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តពិនិត្យសំណើរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ការប្រើប្រាស់ក្របខណ្ឌ មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត
- បន្តធ្វើសមទិន្នព័ត៌មានទៅក្នុងសលាកប័ត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិល
- បន្តការវិភាគមុខងារនិងរចនាសម្ព័ន្ធ ព្រមទាំងការប្រើប្រាស់ធនធានមនុស្ស របស់ក្រសួងស្ថាប័ន សំខាន់ៗមួយចំនួន ដូចជាក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តធ្វើការវិភាគមុខងារ និង រំហូរការងារសម្រាប់សេវាសាធារណៈដែលមានផលប៉ះពាល់ដោយផ្ទាល់លើជីវភាពប្រចាំថ្ងៃរបស់មន្ត្រីរាជការនិងប្រជាពលរដ្ឋ ដូចជា ការបើកផ្តល់ប្រាក់បេសកកម្មដល់មន្ត្រីរាជការ ការផ្តល់ប្រាក់ឧបត្ថម្ភនិងប្រាក់សោធននិវត្តន៍ដល់និវត្តជន ការចុះបញ្ជីយានយន្ត ការចុះបញ្ជីដីធ្លី ការចុះអាជីវកម្ម ការផ្តល់អាជ្ញាបណ្ណសាងសង់ ការផ្តល់សំបុត្រអគ្រានុកូលដ្ឋាន អត្តសញ្ញាណបណ្ណ និងលិខិតឆ្លងដែនជាដើម។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ[illegible] ឆ្នាំ២០១៦

ជ.រដ្ឋមន្ត្រី

**រដ្ឋលេខាធិការ**

**យូ ស៊ុនឡុង**